ជំនួយស្មារតី

វ៉ុលទី២ លេខទី២ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០

# កម្ពុជា និងប្រព័ន្ធអនុគ្រោះពន្ធ EBA៖ តើមានផលប៉ះពាល់បែបណាខ្លះ?”

ជា មុយគីម * និង ចាន់ ផល្លីកា**

គណៈកម្មការអឺរ៉ុប រំពឹងថានឹងប្រកាសអំពីសេចក្ដីសម្រេចទាក់ទងនឹងគោលការណ៍អនុគ្រោះពន្ធរបស់កម្ពុជា នៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០២០ ដែលមានរយៈពេលសរុបមួយឆ្នាំគត់ បន្ទាប់ពីគណៈកម្មការអឺរ៉ុប បានចាប់ផ្ដើមនីតិវិធីដើម្បីដកប្រព័ន្ធអនុគ្រោះពន្ធជាបណ្ដោះអាសន្ន ពីកម្ពុជាជាផ្លូវការនាថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ កន្លងទៅ។ នៅក្នុងសេចក្ដីប្រកាសព័ត៌មាននាថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ ទាក់ទងនឹងសេចក្ដីសម្រេចរបស់គណៈកម្មការ ថាតើត្រូវព្យួរស្ថានភាពអនុគ្រោះពន្ធពីកម្ពុជា ឬយ៉ាងណា គណៈកម្មការអឺរ៉ុបបានសម្រេចដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធពីកម្ពុជា។ សេចក្ដីសម្រេចនេះនឹងមានសុពលភាពចាប់ពីខែសីហា ឆ្នាំ២០២០ តទៅ ពោលគឺរយៈពេលប្រាំមួយ (០៦) ខែ បន្ទាប់ពីការសម្រេចចិត្តត្រូវបានធ្វើឡើង បើសិនមិនមានការជំទាស់ពីសភាអឺរ៉ុប និងក្រុមប្រឹក្សាសហភាពអឺរ៉ុប។ ការដកផ្នែកខ្លះនេះ មានន័យថាទំនិញមួយចំនួនរបស់កម្ពុជា ដែលត្រូវនាំចេញទៅកាន់ទីផ្សារអឺរ៉ុបនឹងត្រូវស្ថិតក្រោមកាតព្វកិច្ចបង់ពន្ធអាករ ខណៈដែលទំនិញដទៃផ្សេងទៀត នៅតែទទួលបានការអនុគ្រោះពន្ធដដែល (European Commission, 2020)។ បើយោងតាមសេចក្ដីប្រកាសព័ត៌មានដដែល ផលិតផលកាត់ដេរ និងស្បែកជើងមួយផ្នែក ព្រមទាំងទំនិញសម្រាប់ធ្វើដំណើរ និងផលិតផលស្ករទាំងអស់ដែលនាំចេញពីកម្ពុជាចូលទៅទីផ្សារអឺរ៉ុប នឹងត្រូវដាក់បញ្ចូលទៅក្នុងបញ្ជីផលិតផលដែលត្រូវបង់ពន្ធ។ ផលប៉ះពាល់នៃការដកផ្នែកខ្លះនេះ មកលើកម្ពុជាត្រូវបានគណនាថា អាចនឹងមានតម្លៃប្រមាណ ១,១ ពាន់លានដុល្លារអាមេរិក ឬស្មើនឹង២០ភាគរយនៃតម្លៃនាំចេញសរុបពីកម្ពុជាទៅកាន់ទីផ្សារអឺរ៉ុប។

រឿងរ៉ាវនៅពីក្រោយនីតិវិធីព្យួរប្រព័ន្ធអនុគ្រោះពន្ធ “អ្វីៗគ្រប់យ៉ាងលើកលែងតែអាវុធ” ឬ EBA នេះ ពីកម្ពុជាបានកើតឡើងបន្ទាប់ពីគណៈកម្មការអឺរ៉ុប បានបើកការស៊ើបអង្កេតផ្ដោតលើអ្វីដែលគេហៅថា “ការរំលោភបំពានធ្ងន់ធ្ងរ និងមានលក្ខណៈជាប្រព័ន្ធ” ទៅលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ និងអង្គការពលកម្មអន្តរជាតិស្ដីពីសិទ្ធិមនុស្ស និងសិទ្ធិការងារស្នូល (European Commission, 2019a)។ គោលការណ៍នៃការដកប្រព័ន្ធអនុគ្រោះពន្ធពីប្រទេសទទួលផល គឺផ្អែកលើមាត្រា១៩នៃបទបញ្ញត្តិរបស់ប្រព័ន្ធអនុគ្រោះពន្ធទូទៅ (ឬ

*ជា មុយគីម គឺជាអ្នកសម្របសម្រួលផ្នែកស្រាវជ្រាវ និងបោះពុម្ពផ្សាយ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

** ចាន់ ផល្លីកា គឺជាអ្នកស្រាវជ្រាវ នៅមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា និងកំពុងសិក្សាថ្នាក់អនុបណ្ឌិតជំនាញគោលនយោបាយសន្តិសុខអន្តរជាតិនៅសាកលវិទ្យាល័យ Université Catholique de Lille ប្រទេសបារាំង។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

ហៅជាភាសាអង់គ្លេសថា GSP – General System of Preferences) ទាក់ទងនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ និងជាប្រព័ន្ធនៃអនុសញ្ញាស្នូលទាំង១៥ របស់អង្គការសហប្រជាជាតិ និងអង្គការពលកម្មអន្តរជាតិ។ នេះគឺជាការបកស្រាយផ្លូវការដោយគណៈកម្មការអឺរ៉ុបទាក់ទងនឹងសេចក្តីសម្រេចដ៏ចម្រូងចម្រាសស្តីពីការដកផ្នែកខ្លះ នៃប្រព័ន្ធអនុគ្រោះពន្ធ EBA ពីកម្ពុជា។

នីតិវិធីនៃការដកបណ្តោះអាសន្នត្រូវបានផ្តួចផ្តើម ដោយគណៈកម្មការអឺរ៉ុប។ ដំបូងបង្អស់ គណៈកម្មការអឺរ៉ុបបានចាប់ផ្តើមការស៊ើបអង្កេត ដើម្បីស្វែងរកយុត្តិកម្មគ្រប់គ្រាន់សម្រាប់សំណើនីតិវិធីដកជាបណ្តោះអាសន្នមួយនេះកាលពីឆ្នាំកន្លងទៅ។ បន្ទាប់ពីការវាយតម្លៃត្រូវបានបញ្ចប់ គេចាប់ផ្តើមអនុវត្តនីតិវិធីបន្តបន្ទាប់មួយចំនួនទៀត ដូចជាការត្រួតពិនិត្យ និងវាយតម្លៃ ការធ្វើរបាយការណ៍ និងផ្តល់អនុសាសន៍ ការទំនាក់ទំនងរវាងគណៈកម្មការ និងប្រទេសទទួលផល ហើយចុងក្រោយ គឺការសម្រេចជាផ្លូវការរបស់គណៈកម្មការអឺរ៉ុបផ្ទាល់។ គណៈកម្មការអឺរ៉ុប បានដើរតួជាអ្នកអនុម័តផង និងអនុវត្តសកម្មភាពផង ក៏ដូចជាអ្នកជូនដំណឹងដល់ទៅកាន់សភាអឺរ៉ុប និងក្រុមប្រឹក្សាសហភាពអឺរ៉ុបផងដែរ។ ក្រៅពីការស៊ើបអង្កេតអំឡុងពេលវាយតម្លៃ គណៈកម្មការក៏បានពិចារណាលើរបាយការណ៍ និងអនុសាសន៍ពាក់ព័ន្ធនានាផ្តល់ជូនដោយអង្គភាពរបស់អង្គការសហប្រជាជាតិ និងអង្គការពលកម្មអន្តរជាតិ ក៏ដូចជាព័ត៌មានពីគណៈប្រតិភូសហភាពអឺរ៉ុប ប្រទេសជាសមាជិកសហភាពអឺរ៉ុប សភាអឺរ៉ុប សង្គមស៊ីវិល និងមន្ត្រីពាក់ព័ន្ធលើការងារសិទ្ធិមនុស្សអន្តរជាតិ-ល-។ យោងតាមសេចក្តីសន្និដ្ឋានរបស់ក្រុមប្រឹក្សាសហភាពអឺរ៉ុបទៅលើកម្ពុជាចេញផ្សាយថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨[1] គណៈកម្មការអឺរ៉ុបបានកំណត់បញ្ហាប្រឈមចំនួនបី (០៣) ទាក់ទងនឹងគោលការណ៍ជាមូលដ្ឋាននៃសិទ្ធិមនុស្ស និងសិទ្ធិការងារដែលរួមមាន៖ (១) សិទ្ធិនយោបាយ និងភាពរួមតូចនៃលំហសម្រាប់អ្នកប្រឆាំងបែបប្រជាធិបតេយ្យ និងសង្គមស៊ីវិល (២) បញ្ហាការងារ និងការរឹតត្បិតសេរីភាពរបស់សមាគម និងសិទ្ធិចរចាជាសមូហភាព និង (៣) បញ្ហាដីសម្បទាន ជាពិសេសនៅក្នុងផលិតកម្មស្ករ (European Commission, 2019b)។ ក្រោយពីនីតិវិធីជាបន្តបន្ទាប់ និងការជូនដំណឹងពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅកាន់រាជរដ្ឋាភិបាលកម្ពុជាជារឿយៗ គណៈកម្មការក៏បានសម្រេចអនុវត្តជំហានបន្ទាប់ ដោយបានបោះពុម្ពផ្សាយសេចក្តីសម្រេច ស្តីការចាប់ផ្តើមនីតិវិធីជាផ្លូវការក្នុងការសម្រេចដកប្រព័ន្ធអនុគ្រោះពន្ធ EBA ពីប្រទេសកម្ពុជានៅក្នុងទិន្នានុប្បវត្តិផ្លូវការរបស់សហភាពអឺរ៉ុប។

កម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសទាំង៤៨ ដែលត្រូវបានអនុញ្ញាតឱ្យនាំចូលទំនិញទៅកាន់ទីផ្សារអឺរ៉ុប ដោយមិនជាប់ពន្ធនាំចូល និងកូតាក្រោមប្រព័ន្ធអនុគ្រោះពន្ធ EBA។ ដោយសារលក្ខណៈអំណោយផលរបស់វា ប្រព័ន្ធអនុគ្រោះពន្ធ EBA ពិតជាមានសារសំខាន់ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា ជាពិសេសនៅក្នុងឧស្សាហកម្មកាត់ដេរ។ ដូចទៅនឹងគោលបំណងដែលបានចែង ប្រព័ន្ធអនុគ្រោះពន្ធ EBA គឺសំដៅជួយដល់ប្រទេសដែលមានការអភិវឌ្ឍតិចតួចបំផុតក្នុងកិច្ចខិតខំប្រឹងប្រែង របស់ពួកគេ ដើម្បីកាត់បន្ថយភាពក្រីក្រ លើកកម្ពស់អភិបាលកិច្ចល្អ និងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព ដោយបង្កើតប្រាក់ចំណូលបន្ថែមតាមរយៈពាណិជ្ជកម្មអន្តរជាតិចូលទៅកាន់ទីផ្សារសហភាពអឺរ៉ុប

[1] សូមមើល See Council of the European Union. (26 February, 2018). *Council conclusions on Cambodia.* Available at: http://data.consilium.europa.eu/doc/document/ST-6416-2018-INIT/en/pdf.

(European Commission, 2019b)។ ហេតុនេះ សហភាពអឺរ៉ុបបានក្លាយជាដៃគូពាណិជ្ជកម្មធំជាងគេរបស់កម្ពុជា ដែលក្នុងនោះការនាំចេញសរុបពីកម្ពុជាទៅសហភាពអឺរ៉ុប មានចំនួនប្រមាណ ៥,៨ ពាន់លានដុល្លារអាមេរិក (European Commission, 2019c)។ មិនត្រឹមតែប៉ុណ្ណោះ ៩៥ភាគរយនៃការនាំចេញទាំងនោះ ស្ថិតក្រោមប្រព័ន្ធ EBA ដែលជាសមាមាត្រខ្ពស់បំផុតទី២ ក្នុងចំណោមបណ្តាប្រទេសទាំងអស់ដែលបានទទួលផលពី ប្រព័ន្ធ EBA។ ការនាំចេញរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុបបានកើនឡើង ៦៣០ (ប្រាំមួយរយសាមសិប)ភាគរយ បើធៀបទៅនឹងឆ្នាំ២០០៨ ជាហេតុដែលគេអាចវាយតម្លៃបានថា ទោះបីជាតិច ឬច្រើន វាជាចំណែកចូលរួមដល់លំនឹងនៃកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧ ភាគរយប្រចាំឆ្នាំរបស់កម្ពុជា ក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ និងបានជួយប្រជាជនស្ទើរតែមួយភាគបីនៃប្រជាជនសរុបរបស់កម្ពុជា ឱ្យចេញពីបន្ទាត់នៃភាពក្រីក្រ (European Parliament, n.d.)។ ដូចបានលើកឡើងនៅខាងដើម ឧស្សាហកម្មកាត់ដេរ និងវាយនភ័ណ្ឌ គឺជាវិស័យទទួលផលធំជាងគេ ក្រោមប្រព័ន្ធនេះ ដែលមានចំនួនប្រហែលបីភាគបួននៃការនាំចូលសរុបរបស់សហភាពអឺរ៉ុបពីកម្ពុជា ហើយក្នុងនោះប្រជាជនកម្ពុជាប្រមាណពីរលាននាក់ រួមទាំងកម្មកររោងចក្រ និងគ្រួសាររបស់ពួកគេផ្ទាល់ ពឹងផ្អែកស្ទើរទាំងស្រុងលើឧស្សាហកម្មកាត់ដេរនេះ។ ដោយបានមើលឃើញពីសារសំខាន់នៃប្រព័ន្ធអនុគ្រោះពន្ធ EBA ទៅលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ការបាត់បង់ការប្រព័ន្ធនេះអាចនឹងជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់សកម្មភាព និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា ក៏ដូចជាសុខុមាលភាពសង្គមរបស់ប្រជាជន ជាពិសេសអ្នកដែលនៅថ្នាក់មូលដ្ឋាន និងអ្នកដែលទទួលផលពីវិស័យទាំងនេះ។

## ទំហំពាណិជ្ជកម្មកម្ពុជា-សហភាពអឺរ៉ុប




*ប្រភព៖ គណៈកម្មការអឺរ៉ុប*

### ❖ មូលដ្ឋានរបស់គណៈកម្មការអឺរ៉ុបលើការដកប្រព័ន្ធអនុគ្រោះពន្ធ EBA និងប្រតិកម្មរបស់កម្ពុជា

ផ្អែកតាមការយល់ឃើញរបស់សហភាពអឺរ៉ុប ការចាត់វិធានលើការគៀបសង្កត់នយោបាយ គឺជាបញ្ហាដែលកើតមានជាយូរមកហើយនៅកម្ពុជា។ គណៈកម្មការអឺរ៉ុប បានសម្តែងការព្រួយបារម្ភមួយចំនួនលើអ្វីដែលគេចាត់ទុកថា ជាការរំលោភសិទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅក្នុងប្រទេស ជាពិសេសលើការចាប់ខ្លួនអតីតមេដឹកនាំគណបក្សប្រឆាំង លោក កឹម សុខា ក្នុងឆ្នាំ២០១៧ និងការរំលាយគណបក្សរបស់គាត់ ព្រមទាំងការបង្ក្រាបលើប្រព័ន្ធផ្សព្វផ្សាយមួយចំនួន ដែលជាសំណុំនៃការចោទប្រកាន់ដែលរដ្ឋាភិបាលកម្ពុជាបានបដិសេធ។ ការដកប្រព័ន្ធអនុគ្រោះពន្ធលើទំនិញនាំចេញរបស់កម្ពុជា ត្រូវបានសហភាពអឺរ៉ុបរំពឹងថាជាឧបករណ៍ដ៏មានប្រសិទ្ធិភាពក្នុងការធ្វើឱ្យកម្ពុជាត្រលប់មកពង្រឹងស្ថានភាពសិទ្ធិមនុស្ស និងស្តារលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសឡើងវិញ។

រាជរដ្ឋាភិបាលកម្ពុជា បានសម្តែងការសោកស្តាយយ៉ាងខ្លាំងហើយបានចាត់ទុកសេចក្តីសម្រេចដកផ្នែកខ្លះនៃប្រព័ន្ធEBA ពីកម្ពុជា ថាជាការសម្រេចចិត្តដ៏អយុត្តិធម៌ តាមរយៈសេចក្តីថ្លែងការណ៍ផ្លូវការរបស់ក្រសួងការបរទេសកម្ពុជា[2] ធ្វើឡើងតែប៉ុន្មានម៉ោងប៉ុណ្ណោះបន្ទាប់ពីសេចក្តីប្រកាសព័ត៌មានរបស់គណៈកម្មការអឺរ៉ុប[3] ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ ត្រូវបានចេញផ្សាយជាសាធារណៈ។ កម្ពុជាបានចាត់ទុកការសម្រេចនេះថាអយុត្តិធម៌ ដោយបានអះអាងថាគណៈកម្មការបានមើលរំលងការប្តេជ្ញាចិត្តរបស់កម្ពុជា ព្រមទាំងវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដែលសម្រេចឡើងដោយរាជរដ្ឋាភិបាលកម្ពុជាឆ្លើយតបនឹងការព្រួយបារម្ភរបស់គណៈកម្មការអឺរ៉ុប រួមមានការដកបណ្តឹងចោទប្រកាន់លើអ្នកនយោបាយ សកម្មជនសង្គមស៊ីវិល និងអ្នកសារព័ត៌មានមួយចំនួន ការធ្វើវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលបានអះអាងថាអាចអនុញ្ញាតឱ្យមានលំហធំជាងមុន សម្រាប់បុគ្គលដែលធ្លាប់មានការរឹតត្បិតខាងនយោបាយ ក្នុងចំណោមកិច្ចខិតខំប្រឹងប្រែងដទៃទៀត។ យ៉ាងណាមិញ កិច្ចខិតខំប្រឹងប្រែងរបស់សហភាពអឺរ៉ុប ក្នុងការប៉ុនប៉ងស្តារលទ្ធិប្រជាធិបតេយ្យ និងពង្រឹងសិទ្ធិមនុស្សតាមរយៈប្រព័ន្ធអនុគ្រោះពន្ធ EBA មិនមែនអនុវត្តតែចំពោះកម្ពុជាតែឯងនោះទេ ប៉ុន្តែក៏ត្រូវបានប្រើលើបង់ក្លាដែស និងមីយ៉ាន់ម៉ា ក្នុងករណីស្រដៀងគ្នា ដែលប្រទេសទាំងពីរនេះ ក៏ត្រូវបានកំណត់ថា ស្ថិតក្រោមការរំលោភសិទ្ធិមនុស្ស និងសិទ្ធិការងារមូលដ្ឋានយ៉ាងធ្ងន់ធ្ងរ។

ដូច្នេះ តើវាមានន័យយ៉ាងណាសម្រាប់កម្ពុជា ក្នុងស្ថានភាពដែលគណៈកម្មការអឺរ៉ុប សម្រេចដកផ្នែកខ្លះនៃការអនុគ្រោះពន្ធនេះ? ដូចអ្វីដែលសេចក្តីប្រកាសព័ត៌មានរបស់គណៈកម្មការអឺរ៉ុបបានព្យាករថា កម្ពុជានឹងខាតបង់ថវិកាប្រមាណ ១,១ ពាន់លានដុល្លារអាមេរិក ចំណាយសម្រាប់ពន្ធលើវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងស្ពរ។ យ៉ាងណាក្តី គេអាចប្រមើលឃើញ សេណារីយ៉ូយ៉ាងហោចណាស់ពីរទៅបី ដែលអាចកើតចេញពីការសម្រេចចិត្តមួយនេះ។ ទីមួយ សេចក្តីសម្រេចនាថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ បានលើកឡើងហើយថា កិច្ចសហការរវាងគណៈកម្មាការអឺរ៉ុប និរាជរដ្ឋាភិបាល

[2] សូមមើល Ministry of Foreign Affairs and International Cooperation. (12 February, 2020). *Statement of the Ministry of Foreign Affairs and International Cooperation on the Decision of the European Commission on Tariffs Preferences under the EBA regime.* Retrieved from: https://www.mfaic.gov.kh/site/detail/40591.

[3] សូមមើល European Commission. (12 February, 2020). Trade/Human Rights: Commission decides to partially withdraw Cambodia's preferential access to the EU market. Retrieved from: https://ec.europa.eu/commission/presscorner/detail/en/ip_20_229.

កម្ពុជា ក្នុងការបន្តដោះស្រាយ និងតាមដានស្ថានការណ៍ ជាពិសេសទាក់ទងនឹងសិទ្ធិមនុស្ស និងស្ថានភាពសិទ្ធិការងារ នៅតែកំពុងបន្ត ដែលជាហេតុផលនៃឲ្យសហភាពអឺរ៉ុបធ្វើការវាយតំលៃ និងពិនិត្យឡើងវិញនូវសេចក្តីសម្រេច ក៏ដូចជាលទ្ធភាពក្នុងការផ្តល់ការអនុគ្រោះពន្ធ EBA ពេញលេញឡើងវិញ សម្រាប់ផលិតផលកម្ពុជានាំចេញទៅទីផ្សារអឺរ៉ុប ប្រសិនបើមានការរីកចម្រើនគួរឲ្យកត់សម្គាល់ លើបញ្ហាដែលបានលើកឡើងដោយគណៈកម្មការអឺរ៉ុប។ ប៉ុន្តែមែនទែនទៅ គេដឹងថា កម្ពុជា ក៏មិនអាច ឬមិនគួរនៅតែបន្តពឹងផ្អែកលើ EBA ដែរ ដូចអ្វីដែលសាធារណជនជាច្រើនក្នុងស្រុក ជាពិសេសក្រុមអ្នកគាំទ្ររដ្ឋាភិបាល បានលើកឡើងជាបន្តបន្ទាប់អំពីការឆក់យកឱកាសនេះ ដើម្បីរួបរួមគ្នាក្នុងគ្រាលំបាក និងបន្តខិតខំជំរុញអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាជាងនៅតែបន្តពឹងផ្អែកលើជំនួយបរទេស និងប្រព័ន្ធអនុគ្រោះពន្ធដូចជា EBA នេះជាដើម។ បន្ថែមពីលើនេះ សេណារីយ៉ូទី២ ក៏ទំនងបង្ហាញថា វាក៏អាចមានការដាក់សម្ពាធបន្ថែមមកលើកម្ពុជាដែរ ព្រោះថាក្នុងពេលបច្ចុប្បន្ននេះ ការសម្រេចចិត្តរបស់គណៈកម្មការអឺរ៉ុប ស្តីពីការដកប្រព័ន្ធអនុគ្រោះពន្ធ EBA ពីកម្ពុជា គឺមានលើផ្នែកខ្លះប៉ុណ្ណោះ ដែលមានន័យថា គណៈកម្មការអឺរ៉ុបនៅតែមានសិទ្ធិ និងឱកាសបន្តលើកឡើងពីការព្រួយបារម្ភដដែលៗ ឬផ្សេងបន្ថែមទៀតកាន់តែច្រើន ទៅលើអាជ្ញាធរកម្ពុជានាពេលខាងមុខ។ ប្រសិនបើករណីនេះកើតមានពិតមែន ហើយបើយកតួលេខនៅក្នុងសេចក្តីសម្រេចកាលពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ មកធ្វើជាគោល កម្ពុជានឹងទទួលរងផលប៉ះពាល់យ៉ាងខ្លាំងចំពោះការនាំចេញរបស់ខ្លួន ក៏ដូចជាចំពោះសេដ្ឋកិច្ចទាំងមូល។ ការខាតបង់ចំពោះមុខធំបំផុត គឺការខាតបង់ទៅលើកាតព្វកិច្ចពន្ធប្រមាណជា៩៥ភាគរយ លើទំនិញនាំចេញទៅអឺរ៉ុប ដែលធ្លាប់តែស្ថិតនៅក្រោមប្រព័ន្ធអនុគ្រោះពន្ធ។ បើនិយាយពីស្ថិតិ គឺនឹងមានការខាតបង់ពន្ធដែលត្រូវបង់ទៅលើទំនិញដែលមានតម្លៃប្រមាណ ៥,៥ ពាន់លានដុល្លារ។ ក្នុងន័យនេះដែរ វានឹងមានការបន្ថែមពន្ធគយ ១២ភាគរយ លើការនាំចេញសម្លៀកបំពាក់ និងចន្លោះពី ៨ ទៅ ១៧ភាគរយលើការនាំចេញស្បែកជើង (Turton, 2020)។ ឯកឧត្តម វង្សី វិស្សុត ក្នុងនាមជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានព្យាករថាការនាំចេញវិស័យកាត់ដេរ អាចមានការធ្លាក់ចុះប្រហែល ៥០០ លានដុល្លារ និងអាចមានមនុស្សបាត់បង់ការងារចំនួន៣ម៉ឺន ៥ពាន់នាក់ ក្នុងចំណោមកម្មកររោងចក្រ ប្រមាណ៧៥ម៉ឺននាក់ (Aun, 2020)។ ដោយសារ សហភាពអឺរ៉ុបនៅតែបន្តបង្ហាញការព្រួយបារម្ភទៅលើស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ទោះបីរាជរដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ជាបន្តបន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងជាវិជ្ជមានដើម្បីឆ្លើយតបទៅនឹងការព្រួយបារម្ភទាំងនេះ ដូច្នេះ លទ្ធភាពដែលសហភាពអឺរ៉ុប នឹងបន្តដាក់សម្ពាធមកលើកម្ពុជាដោយប្រើប្រព័ន្ធអនុគ្រោះពន្ធ EBA ជាឧបករណ៍ នៅតែមានជានិច្ច។ ដូច្នេះ តិចក្តី ឬច្រើនក្តី កម្ពុជា គួរពិចារណាពីលទ្ធភាពដែលសេណារីយ៉ូបែបនេះអាចកើតឡើង ហើយត្រូវត្រៀមលក្ខណៈឱ្យបានល្អដើម្បីទប់ទល់។ សេណារីយ៉ូចុងក្រោយ គឺស្របពេលដែលមានការព្រួយបារម្ភដ៏ចម្រូងចម្រាសស្តីពីការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធ EBA នោះ គេត្រូវដឹងថា ការបាត់បង់នេះ គឺជាអ្វីមួយដែលមុខតែនឹងកើតឡើង វាគ្រាន់តែមុន និងក្រោយប៉ុណ្ណោះ ពីព្រោះថាការលើកលែងកាតព្វកិច្ចពន្ធនេះ មិនត្រូវបានផ្តល់ដល់ប្រទេសទទួលផលណាមួយជារៀងរហូតឡើយ។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់នេះនឹងជះឥទ្ធិពលយ៉ាងខ្លាំងដល់សេដ្ឋកិច្ចកម្ពុជា ហើយវាអាចនឹងបន្តយូរគួរសម ដោយហេតុថា និយតកម្ម (របស់នីតិវិធី) ត្រូវការរយៈពេលប្រាំមួយ (០៦) ខែមុននឹងសេចក្តីសម្រេច

ចូលជាធរមាន។ ដូចនេះ ការរៀបចំខ្លួនរបស់កម្ពុជា គឺមានរយៈពេលខ្លី។ ទោះជាយ៉ាងណា កម្ពុជាគួរសម្លឹងមើលបញ្ហានេះក្នុងន័យវិជ្ជមាន ព្រោះថាប្រព័ន្ធអនុគ្រោះពន្ធ EBA មិនមែនជាអ្វីៗគ្រប់យ៉ាង ហើយក៏មិនមែនជាកត្តាតែមួយគត់ ដែលបានជួយឱ្យកម្ពុជាដើរមកដល់ចំណុចនេះ និងឆ្ងាយជាងនេះថែមទៀតនាពេលអនាគតដ៏វែងទៅមុខ ដូចពាក្យមួយឃ្លាពោលថា "ពេលទ្វារមួយបិទ នឹងមានទ្វារមួយទៀតបើក"។ ក្នុងនាមជាប្រទេសឯករាជ្យ ជាជាងនៅខ្វល់ជាមួយបញ្ហាដែលមិនមែននៅក្រោមសមត្ថកិច្ច ឬក្រោមការសម្រេចចិត្តរបស់ខ្លួនបែបនេះ កម្ពុជាគប្បីប្រើឱកាសនេះដើម្បីរក្សាជំហរ និងរួបរួមគ្នាជាធ្លុងមួយក្នុងការស្វែងរកការចចារ និងការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយដៃគូដែលមានសក្តានុពល ដើម្បីពង្រីកទីផ្សារ និងពង្រឹងកម្លាំងពលកម្មជំនាញ ព្រមទាំងបន្តជំរុញបន្ថែមទៀតនូវការផ្លាស់ប្តូរឌីជីថល និងឧស្សាហកម្ម ក៏ដូចជាការធ្វើពិពិធកម្ម ផលិតកម្មនិងការបង្កើនប្រាក់ចំណូលសម្រាប់ប្រទេសជាដើម។ តួយ៉ាងដូចជាករណី Brexit ជាដើម ដែលចក្រភពអង់គ្លេសបានលាលែងពីសមាជិកភាពនៃសហភាពអឺរ៉ុបជាផ្លូវការ កម្ពុជាគប្បីស្វះស្វែងរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ជាមួយចក្រភពអង់គ្លេស។ ចក្រភពអង់គ្លេស ជាក់ស្តែង គឺជាទីផ្សារទទួលទំនិញពីកម្ពុជាដ៏ធំជាងគេមួយទៅកាន់ទីផ្សារអឺរ៉ុប ដែលក្នុងនោះទឹកប្រាក់ចំនួន ១ ពាន់លានដុល្លារអាមេរិកនៃទឹកប្រាក់សរុប ៥,៥ ពាន់លានដុល្លារអាមេរិកលើការនាំចេញពីកម្ពុជាទៅអឺរ៉ុប បានមកពីចក្រភពអង់គ្លេស (Phoung, 2020)។ លើសពីនេះ ទីផ្សារដៃគូសំខាន់ៗដទៃទៀតមានដូចជា ចិន កូរ៉េខាងត្បូង ជប៉ុន និងបណ្តាដៃគូសន្ធនាអាស៊ាន និងក្របខណ្ឌ RCEP ( Regional Comprehensive Economic Partnership ) ដែលសុទ្ធតែជាដៃគូពាណិជ្ជកម្មដ៏មានសក្តានុពលសម្រាប់កម្ពុជា។ ជាមួយគ្នានេះ ជុំទីមួយនៃការចរចាស្តីពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និងចិន គឺជាអ្វីដែលគេសង្កេតឃើញ និងរំពឹងទុក ពោលគឺកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី ដែលអាចបានទទួលលទ្ធផលជាផ្លែផ្កា ខណៈដែលតំណាងជាន់ខ្ពស់រវាងប្រទេសទាំងពីរ រំពឹងថាការរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងកម្ពុជា និងចិននេះ នឹងចេញជារូបរាងក្នុងពេលខាងមុខ ដោយមិនចាំបាច់ត្រូវរង់ចាំយូរទេ។ ក្រៅពីនេះ កម្ពុជាក៏អាចជ្រើសរើសការធ្វើពិពិធកម្មផលិតផលទៅកាន់ទីផ្សារនៃប្រទេសគោលដៅដទៃផ្សេងទៀតដែលមានតម្រូវការប្រហាក់ប្រហែលនឹងទីផ្សារអឺរ៉ុប តែតម្លៃដែលត្រូវបង់ពន្ធទាបជាងទីផ្សារអឺរ៉ុប។ ខណៈដែលការព្រួយបារម្ភអំពីការបាត់បង់ប្រព័ន្ធអនុគ្រោះពន្ធ EBA កាន់តែកើនឡើង ការនាំចេញអង្ករទៅកាន់សហភាពអឺរ៉ុបបានចាប់ផ្តើមធ្លាក់ចុះ ចាប់ពី ៣០០.០០០តោន ក្នុងឆ្នាំ២០១៨ មកនៅត្រឹម ២០០.០០០ តោន ក្នុងឆ្នាំ២០១៩ (Hutt, 2020) តែការធ្លាក់ចុះនៃការនាំចេញអង្ករទៅកាន់សហភាពអឺរ៉ុបនេះ ត្រូវបានជំនួសដោយការកើនឡើងប្រមាណ ៤៦ ភាគរយនៃការនាំចេញអង្ករទៅប្រទេសចិន។

បើមើលឲ្យច្បាស់ទៅ ផលប៉ះពាល់នៃសេចក្តីសម្រេចរបស់គណៈកម្មការអឺរ៉ុបនេះ មិនមែនតែមានកម្ពុជាម្ខាងប៉ុណ្ណោះទេ តែសហភាពអឺរ៉ុបក៏អាចនឹងត្រូវរងការប៉ះពាល់ដូចគ្នាផងដែរ ព្រោះថានៅពេលកម្ពុជាចាប់ផ្តើមធ្វើពិពិធកម្មទីផ្សារនាំចេញរបស់ខ្លួនទៅកាន់ទិសដៅទីផ្សារនៃប្រទេសដទៃទៀតក្រៅពីទីផ្សារអឺរ៉ុប សហភាពអឺរ៉ុបខ្លួនឯងក៏ត្រូវស្វែងរកទីផ្សារនាំចូលថ្មីដូចគ្នាដើម្បីមកជំនួសផលិតផលដែលធ្លាប់បាននាំចូលពីកម្ពុជា។ ប៉ុន្តែ វាអាចនឹងមិនមែនជារឿងងាយស្រួលនោះទេ ព្រោះដោយម្យ៉ាង អឺរ៉ុបនឹងត្រូវស្វែងរកប្រទេសនាំចេញដែលមានកម្លាំងពលកម្មទាប និងមានតម្លៃសមរម្យស្រដៀងគ្នា

ទៅនឹងកម្ពុជា ឯម្យ៉ាងវិញទៀតអ្នកប្រើប្រាស់ក្នុងសហភាពអឺរ៉ុបក៏នឹងត្រូវស្វែងរកសម្ភារប្រើប្រាស់ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងផលិតផលនាំចូលពីកម្ពុជា។

មកទល់ពេលនេះ ប្រព័ន្ធអនុគ្រោះពន្ធ EBA បានដើរតួជាជំនួយពាណិជ្ជកម្មមួយដ៏សំខាន់ដល់សេដ្ឋកិច្ចរបស់កម្ពុជាក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ តែវាក៏បានបង្កឱ្យមានការព្រួយបារម្ភដល់មនុស្សជាច្រើនដោយសារវាដូចគ្នា។ ការដកប្រព័ន្ធអនុគ្រោះពន្ធនេះ នឹងមានផលប៉ះពាល់យ៉ាងខ្លាំងដល់ការអភិវឌ្ឍរបស់ប្រទេស ហើយសំខាន់បំផុត គឺលើវិស័យកាត់ដេរ។ តែបើទោះបីជា គណៈកម្មការបានចេញសេចក្តីសម្រេចរបស់ខ្លួនលើករណី EBA សម្រាប់កម្ពុជាយ៉ាងណាក៏ដោយ វាក៏មិនទាន់ចប់នៅឡើយដែរ ព្រោះដើម្បីឱ្យសេចក្តីសម្រេចនេះចូលជាធរមាន លុះត្រាតែមិនមានការមិនជំទាស់ពីសភាអឺរ៉ុប និងក្រុមប្រឹក្សាសហភាពអឺរ៉ុប។ និយាយរួមទៅបើសេចក្តីសម្រេចលើការដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធ EBA ពីកម្ពុជានេះ មិនមានការជំទាស់ពីស្ថាប័នរបស់សហភាពអឺរ៉ុបទាំង២ ខាងលើទេ សេចក្តីសម្រេចនេះនឹងចូលជាធរមានក្នុងរយៈពេល ៦ខែបន្ទាប់ ពោលគឺនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០។ យ៉ាងណាក្តី គេនៅតែរំពឹងថាសហភាពអឺរ៉ុប ត្រូវពិចារណាលើផលប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់កម្មករ រួមទាំងក្រុមគ្រួសាររបស់ពួកគេសរុបជិតពីរលាននាក់។

## ឯកសារយោង


Aun, C. (10 February, 2020). The Stakes Are High as Cambodia Braces for EU Trade Preferences Decision. *VOA Cambodia.* Retrieved from: https://www.voacambodia.com/a/the-stakes-are-high-as-Cambodia-braces-for-EU-trade-preferences-decision/5281467.html.

European Commission. (11 February, 2019a). *Cambodia: EU launches procedure to temporarily suspend trade preferences.* Retrieved from: https://trade.ec.europa.eu/doclib/press/index.cfm?id=1981&title=Cambodia-EU-launches-procedure-to-temporarily-suspend-trade-preferences.

European Commission. (11 February, 2019b). *EU triggers procedure to temporarily suspend trade preferences for Cambodia.* Retrieved from: https://ec.europa.eu/commission/presscorner/detail/en/MEMO_19_988.

European Commission. (12 November, 2019c). *Cambodia: European Commission finalises preliminary report on temporary suspension of trade preferences.* Retrieved from: https://trade.ec.europa.eu/doclib/press/index.cfm?id=2080.

European Commission. (03 August, 2019d). *European Union, Trade in goods with Cambodia.* Retrieved from: https://webgate.ec.europa.eu/isdb_results/factsheets/country/details_cambodia_en.pdf.

European Commission. (12 February, 2020). *Trade/Human Rights: Commission decides to partially withdraw Cambodia's preferential access to the EU market.* Retrieved from: https://ec.europa.eu/commission/presscorner/detail/en/ip_20_229.

European Parliament. (n.d.). *'Everything but Arms': The case of Cambodia.* Retrieved from: http://www.europarl.europa.eu/RegData/etudes/ATAG/2019/637931/EPRS_ATA(2019)637931_EN.pdf.

Hutt, D. (23 January, 2020). Cambodia rice crisis signals deeper economic rot. *Asia Times.* Retrieved from: https://www.asiatimes.com/2020/01/article/

cambodia-rice-crisis-signals-deeper-economic-rot/

Ministry of Foreign Affairs and International Cooperation. (19 February, 2019). *Statement of the Royal Government of Cambodia in response to the European Commission's decision to launch the formal procedure for the temporary withdrawal of the Everything But Arms (EBA) preferences for Cambodia.* Retrieved from Open Development: https://opendevelopmentcambodia.net/announcements/statement-of-the-royal-government-of-cambodia-in-response-to-the-european-commissions-decision-to-launch-the-formal-procedure-for-the-temporary-withdrawal-of-the-everything-but-arms-eba-pre/.

Phoung, V. (07 February, 2020). Cambodia Set to Negotiate a Trade Agreement with Post-Brexit United Kingdom. *Thmey Thmey*. Retrieved from: https://cambodianess.com/article/cambodia-set-to-negotiate-a-trade-agreement-with-post-brexit-united-kingdom.

Turton, S. (09 February, 2020). EU to end privileges on some Cambodia exports: lawmaker. *Nikkei Asian Review.* Retrieved from: https://asia.nikkei.com/Economy/Trade/EU-to-end-privileges-on-some-Cambodia-exports-lawmaker.

Cambodia Development Center

Cambodia Development Center (@cd.centerkh)

Cambodia Development Center

Building E, University of Puthisastra, #55, Street 184, Sangkat Boeung Raing, Khan Daun Penh

info@cd-center.com | (+855) 10 950 456

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center